ឯកសារទិន្នន័យគម្រោង (PDS) ដែលបកប្រែនេះ គឺផ្អែកទៅតាមសំណៅភាសាអង់គ្លេស ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥។

ADB

# ឯកសារទិន្នន័យគម្រោង

ឯកសារទិន្នន័យគម្រោង (PDS) រួមមាន ព័ត៌មានសង្ខេបអំពីគម្រោង ឬ កម្មវិធី ៖ ដោយសារតែ PDS គឺជាការងារដែលត្រូវធ្វើជាបន្តបន្ទាប់ ព័ត៌មានមួយចំនួនអាចមិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងសំណៅដំបូងនេះនៅឡើយ ប៉ុន្តែនឹងត្រូវបន្ថែមនៅពេលដែលមាន។ ព័ត៌មានអំពីគម្រោងដែលត្រូវបានស្នើឡើង គឺត្រឹមតែជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

| | |
|---|---|
| កាលបរិច្ឆេទបង្កើត **PDS** | - |
| **PDS** ត្រូវបានធ្វើបច្ចុប្បន្នកម្មត្រឹមកាលបរិច្ឆេទ | ១៩ វិច្ឆិកា ២០១៤ |

| | |
|---|---|
| ឈ្មោះគម្រោង | ពង្រឹងការអប់រំកម្រិតមធ្យមសិក្សា និងការបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ (អតីតកម្មវិធីអភិវឌ្ឍន៏វិស័យអប់រំទី ៤ - ESDP IV) |
| ប្រទេស | កម្ពុជា |
| លេខគម្រោង/កម្មវិធី | ៤៧១៣៦-០០៣ |
| ស្ថានភាព | ត្រូវបានស្នើ |
| ទីតាំងភូមិសាស្ត្រ | – |

នៅក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រប្រចាំប្រទេសណាក៏ដោយ ការផ្តល់ហិរញ្ញប្បទានដល់គម្រោងអ្វីក៏ដោយ ឬការលើកឡើង ឬយោងលើដែនដីឬតំបន់ភូមិសាស្ត្រណាមួយនៅក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ី មិនមានបំណងធ្វើការវិនិច្ឆ័យអំពីស្ថានភាពគតិយុត្ត ឬស្ថានភាពផ្សេងៗរបស់ដែនដី ឬតំបន់នោះឡើយ។

| | |
|---|---|
| ចំណាត់ថ្នាក់វិស័យ និង/ឬអនុវិស័យ | _ |
| ចំណាត់ថ្នាក់ប្រធានបទ | _ |
| ប្រភេទនៃការបញ្ច្រាបយេនឌ័រ | _ |

## ■ ការផ្តល់ហិរញ្ញប្បទាន

| ប្រភេទ/ទម្រង់នៃការផ្តល់ជំនួយ | លេខអនុម័ត | ប្រភពមូលនិធិ | ចំនួនអនុម័ត (គិតជាពាន់) |
|---|---|---|---|
| កម្ចី | – | ធនាគារអភិវឌ្ឍន៍អាស៊ី | ៣០.០០០ |
| សរុប | | | ៣០.០០០ ដុល្លារ |

## ប្រភេទនៃការការពារផ្នែកបរិស្ថាន និងសង្គម

សម្រាប់ព័ត៌មានបន្ថែមអំពីប្រភេទនៃការការពារផ្នែកបរិស្ថាន និងសង្គម សូមមើល:
http://www.adb.org/site/safeguards/safeguard-categories

| | |
|---|---|
| បរិស្ថាន | C |
| ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត | C |
| ក្រុមជនជាតិដើមភាគតិច | B |

## សង្ខេបបញ្ហាបរិស្ថាន និងសង្គម

ទិដ្ឋភាពបរិស្ថាន

-

ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត

-

ក្រុមជនជាតិដើមភាគតិច

-

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

ក្នុងកំឡុងពេលរៀបចំគម្រោង

-

ក្នុងកំឡុងពេលអនុវត្តគម្រោង

-

## សេចក្តីពិពណ៌នា

កម្មវិធីពង្រឹងការអប់រំកម្រិតមធ្យមសិក្សា និងការបង្រៀនគណិតវិទ្យា និង វិទ្យាសាស្ត្រ（កម្មវិធី SSETMS） ត្រូវបានស្នើឡើងបន្ទាប់ពីមានកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំជាច្រើន ដែលមានគោលបំណងគាំទ្រដល់អាទិភាពរយៈពេលវែងរបស់រាជរដ្ឋា-ភិបាលកម្ពុជា ក្នុងការលើកកម្ពស់លទ្ធភាពទទួលបាន និងគុណភាពនៃការអប់រំកម្រិតមធ្យមសិក្សា (SE)។ ដោយត្រូវបានតម្រឹម

ឱ្យស្របជាមួយនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២០១៤-២០១៨ របស់រដ្ឋាភិបាល ដែលនឹងត្រូវបានអនុវត្តនាពេលខាងមុខនេះ កម្មវិធីនេះ នឹងមានដាក់បញ្ចូលនូវកម្មវិធីគោលនយោបាយមួយ ដើម្បីគាំទ្រដល់កំណែទម្រង់នានា សំដៅបង្កើនការបញ្ចប់ការសិក្សាថ្នាក់ទី ១២ ជាពិសេស ក្នុងចំណោមសិស្សក្រីក្រ និងសិស្សស្រី ដែលមកពីតាមតំបន់ដាច់ស្រយាល។ កម្មវិធីវិនិយោគដែលមានភ្ជាប់ទំនាក់ទំនងជាមួយនឹងកម្មវិធីនេះ នឹងផ្តោតជាសំខាន់លើលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងលើកកម្ពស់ការអប់រំផ្នែកវិទ្យាសាស្ត្រ គណិតវិទ្យា និងបច្ចេកវិទ្យា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ កម្មវិធី SSETMS នឹងគាំទ្រដល់ការអនុវត្តអាទិភាពសំខាន់ៗនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨។ SSETMS ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិការធុរកិច្ចប្រចាំប្រទេសរបស់ ADB (COBP ២០១៣-២០១៥) និង ត្រូវបានតម្រឹមឱ្យស្របជាមួយនឹងយុទ្ធសាស្ត្រ ២០២០ និងផែនការប្រតិបត្តិសម្រាប់វិស័យអប់រំ។ នឹងមានការស្វែងយល់បន្ថែមទៀតពីទម្រង់ការផ្តល់កម្ចីផ្អែកតាមលទ្ធផល (RBL) នៅក្នុងកំឡុងបេសកកម្ម PPTA។ កិច្ចពិគ្រោះយោបល់ជាមួយនឹងរដ្ឋាភិបាលបានបង្ហាញឱ្យឃើញពីភាពបើកចំហក្នុងការស្វែងយល់ពីសក្តានុពលនៃទម្រង់ការ RBL នេះ។ SSETMS នឹងអនុវត្តនូវកម្មវិធីសំណាញ់សុវត្ថិភាពសង្គមមួយ ដោយផ្តោតគោលដៅលើកុមារមកពីគ្រួសារក្រីក្រ ដើម្បីឱ្យពួកគេអាចរៀនចប់ថ្នាក់ទី ៩។ កម្មវិធីនេះ នឹងបំពេញបន្ថែមលើអន្តរាគមន៍ផ្សេងៗតាមសាលារៀន ក្រោមកម្មវិធី ESDP III។ កម្មវិធី SSETMS ក៏នឹងឆ្លើយតបទៅនឹងតម្រូវការមិនទាន់បានបំពេញជាច្រើន នៅកម្រិតមធ្យមសិក្សាទុតិយភូមិផងដែរ ហើយកសាងបន្ថែមលើសមិទ្ធផលនានា ដែលសម្រេចបានដោយកម្មវិធី EEQP ពាក់ព័ន្ធនឹង (i) ការអប់រំផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និង (ii) ការអភិវឌ្ឍ ការគ្រប់គ្រង និង និរន្តរភាពនៃមជ្ឈមណ្ឌលធនធានសាលា។ ទីតាំងភូមិសាស្ត្រគោលដៅ នឹងត្រូវបានកំណត់តាមរយៈការភ្ជាប់ទំនាក់ទំនងទិន្នន័យអប់រំ ជាមួយនឹងទិន្នន័យនៃភាពក្រីក្រតាមខេត្ត។

## ■ សង្គតិភាព និងទំនាក់ទំនងរបស់គម្រោងជាមួយនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់

–

## ■ ផលប៉ះពាល់នៃការអភិវឌ្ឍ

ការអប់រំកម្រិតមធ្យមសិក្សាសកល ត្រូវបានបង្កើតឡើង។

## លទ្ធផលរយៈពេលមធ្យមរបស់គម្រោង

| សេចក្តីពិពណ៌នាអំពីលទ្ធផលរយៈពេលមធ្យម | វឌ្ឍនភាពឆ្ពោះទៅសម្រេចលទ្ធផលរយៈពេលមធ្យម |
| --- | --- |
| បង្កើនការចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ | – |

## លទ្ធផល និងវឌ្ឍនភាពនៃការអភិវឌ្ឍ

| សេចក្តីពិពណ៌នាអំពីលទ្ធផលរបស់គម្រោង | ស្ថានភាពនៃការអនុវត្ត (លទ្ធផល សកម្មភាព និងបញ្ហា) |
| --- | --- |
| បង្កើនលទ្ធភាពទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ, លើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនៃការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ, ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងការអប់រំកម្រិតមធ្យមសិក្សា។ | – |
| **ស្ថានភាពនៃគោលដៅអភិវឌ្ឍ** | **ការផ្លាស់ប្តូរសំខាន់ៗ** |
| – | – |

## ឱកាសធុរកិច្ចផ្សេងៗ

| | |
| --- | --- |
| កាលបរិច្ឆេទនៃការចុះបញ្ជីដំបូង | – |

**សេវាពិគ្រោះយោបល់**

–

**លទ្ធកម្ម**

–

**សេចក្តីជូនដំណឹងអំពីលទ្ធកម្ម និងការពិគ្រោះយោបល់:**

http://www.adb.org/projects/47136-003/business-opportunities

## ការវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | ៧ កុម្ភៈ ២០១៤ |
| បេសកកម្មស្វែងរកការពិត | ០៧ តុលា ២០១៣ - ១១ តុលា ២០១៣ |
| កិច្ចប្រជុំពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង | ២ សីហា ២០១៤ |
| ការអនុម័ត | - |
| បេសកកម្មពិនិត្យឡើងវិញចុងក្រោយ | - |

## ចំណុចគោលផ្សេងៗ

| លេខអនុម័ត | ការអនុម័ត | ចុះហត្ថលេខា | ចូលជាធរមាន | បិទ | | |
|---|---|---|---|---|---|---|
| | | | | សំណៅដើម | ត្រូវបានកែសម្រួល | ជាក់ស្តែង |
| _ | _ | _ | _ | _ | _ | _ |

## ការប្រើប្រាស់

| កាលបរិច្ឆេទ | លេខអនុម័ត | ADB (ពាន់ US$) | ផ្សេងៗ (ពាន់ US$) | ភាគរយ |
|---|---|---|---|---|
| ចំនួនសរុបក្នុងការផ្តល់កិច្ចសន្យា | | | | |
| _ | _ | _ | _ | _ |
| ការបើកប្រាក់សរុប | | | | |
| _ | _ | _ | _ | _ |

## ស្ថានភាពនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងត្រូវបានបែងចែកតាមប្រភេទដូចតទៅ - របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងដែលត្រូវបានធ្វើសវនកម្មរួច គោលនយោបាយគាំពារបិស្ថាន /សង្គម វិស័យសង្គម វិស័យហិរញ្ញវត្ថុ វិស័យសេដ្ឋកិច្ច និងវិស័យផ្សេងៗ។ ការអនុលោមទៅតាមកិច្ចព្រមព្រៀងត្រូវបានដាក់ពិន្ទុទៅតាមប្រភេទដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចតទៅ:(១) ពេញចិត្តៈ អនុលោមទាំងអស់ទៅតាមគ្រប់កិច្ចព្រមព្រៀងដោយមានករណីលើកលែងច្រើនបំផុតត្រឹមមួយ ដែលអនុញ្ញាតឱ្យមាន (២)ពេញចិត្តដោយអន្លឹះច្រើនបំផុតមានកិច្ចព្រមព្រៀងចំនួនពីរ ដែលមិនត្រូវបានអនុលោមតាម (៣)មិនពេញចិត្តៈ មានកិច្ចព្រមព្រៀងចាប់ពីបីឡើងទៅដែលមិនត្រូវបានអនុលោមតាម។ យោងតាមគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈឆ្នាំ ២០១១ ការវាយតម្លៃនៃភាពអនុលោម របស់កិច្ចព្រមព្រៀងសម្រាប់របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងអនុវត្តតែចំពោះគម្រោងដែលលិខិតអញ្ជើញឱ្យចរចាក្រោយថ្ងៃទី ២ ខែមេសាឆ្នាំ ២០១២ តែប៉ុណ្ណោះ។

| លេខអនុម័ត | ប្រភេទ | | | | | | |
|---|---|---|---|---|---|---|---|
| | វិស័យ | សង្គម | ហិរញ្ញវត្ថុ | សេដ្ឋកិច្ច | ផ្សេងៗ | ការគាំពារបរិស្ថាន/សង្គម | របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោង |
| កម្ចី | – | – | – | – | – | – | – |

## ផ្នែកទំនាក់ទំនង និងព័ត៌មានបច្ចុប្បន្នភាព

| | |
|---|---|
| មន្ត្រី **ADB** ដែលទទួលខុសត្រូវ | Eiko Izawa (eizawa@adb.org) |
| នាយកដ្ឋាន **ADB** ដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ (SERD) |
| ការិយាល័យ **ADB** ដែលទទួលខុសត្រូវ | ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងសង្គមរបស់ SERD |
| ទីភ្នាក់ងារប្រតិបត្តិ | – |

## ឯកសារសម្រាប់មើលព័ត៌មានផ្សេងៗទៀត

| | |
|---|---|
| គេហទំព័ររបស់គម្រោង | http://www.adb.org/projects/47136-003/main |
| បញ្ជីឯកសារគម្រោង | http://www.adb.org/projects/47136-003/documents |